កំរងរឿងៈ

# នេះឬពូថៅតា




០៨០.
២៦៥

តាហោរា និង តាចាស់ដូនចាស

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh** **www.elibraryofcambodia.org**

# រឿង ទេះបុត្រចេតា ១



SIPAR Prey Veng

តាមសៀវភៅប្រជុំរឿងព្រេងខ្មែររបស់ ពុទ្ធសាសនបណ្ឌិត

ឧបត្ថម្ភបោះផ្សាយដោយអង្គការ ស៊ីប៉ា SIPAR Prey Veng

រៀបសំរួលដោយ ទេព្វី យ៉ាំន  គូរដោយៈ ម៉ុល សារឿន

មានតំណាលតៗគ្នាមកថា មានតា ចាស់ពោះម៉ាយម្នាក់ រស់នៅតែម្នាក់ឯង ក្រីក្រ លំបាកតោកយ៉ាកគ្មានទ្រព្យធន ចិញ្ចឹមជីវិត រាល់ថ្ងៃដោយ កំរៃបានមកពីការ កាប់អុស លក់ ។

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
ខ១១/៩៤



ថ្ងៃនេះដូចថ្ងៃមុនៗដែរ តាឃើង ក្រោកពីព្រលឹម លីពូថៅ ដែលជាសម្បត្តិតែមួយគត់ របស់គាត់ចូលព្រៃ ។

ដល់ក្បែរមាត់បឹងមួយ គាត់ក៏កាប់រំលំ ដើមឈើ១ដើម ។ ចៃដន្យអាក្រក់ ភ័ព្វចង្រៃ ពូថៅក៏របេះពីដៃ ធ្លាក់ទៅក្នុងបឹង ។





តាយើងប្រឹងរកអស់ចំណោះមិនឃើញ សោះគាត់សោកស្តាយ ស្រណោះអស់សង្ឃឹម។ តាយើង លើកដៃទាំងពីរមកផ្ទឹម បន់ស្រន់ទាំង សោកសៅថា÷"ឱពូថៅអើយ! អ្នកបាន ចិញ្ចឹមខ្ញុំ ជាយូរមកហើយ! តើថ្ងៃនេះខ្ញុំសល់អ្វី ទៀតបើអ្នកឃ្លាតពីខ្ញុំទៅហើយនោះ ? សូមទេវតាជួយខ្ញុំផង ខ្ញុំម្តេចអភ័ព្វ ខុសគេដូច នេះ? ។ រំពេចនោះ ស្រាប់តែមានតាសក់ស ម្នាក់ផុសចេញពីក្នុងទឹកបឹង និងស្រដីថា÷



"នែតាដ៏កំសត់ ! ឈប់យំទៅ ចាំយើង ជួយរក"



តាសក់សមុជបាត់ទៅក្នុងទឹក រួចផុសជាថ្មី នៅដៃមានកាន់ពូថៅចាស់មួយ និង ពូថៅ មាសមួយ ។

- ឯណាពូថៅតា ចូរតាមកយកទៅ !

តាយើងឃើញមាសក្រហមឆ្អៅ តែគាត់ មិនយកឡើយ ។ គាត់ទទួលយកពូថៅរបស់គាត់មកវិញ "នេះហើយជាពូថៅដ៏ល្អរបស់ខ្ញុំ"



តាសក់សឃើញតាយើងមានការស្មោះត្រង់ល្អក៏ប្រគល់ពូថៅទាំងពីរអោយតាយើង ។



ចាប់ពីថ្ងៃនោះមក តាយើង

ក៏ក្លាយជាអ្នកមាន រីឯអ្នកស្រុក

ស្រឡាញ់រាប់អានគាត់គ្រប់ៗ

គ្នា ។ គាត់រស់នៅយ៉ាងសុខ

សាន្ត តែគាត់តែងគិតដល់

អ្នកក្រទាំងពួង ។

រឿងនេះមិនស្ងាត់បាត់

ដំណឹងដឹងដល់លោក

សេដ្ឋីទេ ។





ដោយចិត្តលោភលន់ សេដ្ឋីក៏រូតរះជា បន្ទាន់ ធ្វើកលជាអ្នកកាប់អុសដូចតាយើង ។







ទៅដល់មាត់បឹងសេដ្ឋីប្រឹងកាប់ ដោយហត់ពេក គាត់ក៏ប្រញាប់បោះពូថៅចោលក្នុងទឹក រួច អង្គុយយំហ៊ូៗថា ÷

- ទេវតាអើយ ម្តេចមិនជួយរកពូថៅខ្ញុំផង ?

គាត់ធ្វើជាសោកស្តាយអស់សង្ឃឹម គាត់បន់ស្រន់ ហើយបន់ស្រន់ទៀតមាត់ឡើងរៀច ដូចមាត់ខ្យង ។



ស័ក្តិសិទ្ធិដូចបំណង តាសក់ស បានផុសពីទឹកមក ដោយកាន់ពូថៅពីរផង ។ ពូថៅមួយ ជាពូថៅមាស ឯពូថៅមួយទៀតជាពូថៅរបស់សេដ្ឋី ។

- មួយណាជាពូថៅតា ?

- នេះជាពូថៅខ្ញុំ ! ។ សេដ្ឋីចង្អុលពូថៅមាស ហើយ ចុះទៅទទួលយកពូថៅមាស នោះ ។



នៅពេលដែលលោកសេដ្ឋីលូកដៃទៅយកពូថៅមាស តាសក់ស ក៏រលាយបាត់ លេចចេញពស់វែក បើកភ្នែកបញ្ចេញ អណ្តាតភ្លែម១ ។ លោកសេដ្ឋី ភ័យស្លន់ស្លោ ស្ទុះឡើង លើគោក បោកមុខ បោកក្បាលជល់ ដើមឈើ កើតក្តីឈឺចាប់យ៉ាងខ្លាំង ។

"លោភលន់នឹងលាភ វែងបាត់ធនទៅ"




සසි



# រឿង កុមារគឹម និង អ្នកតាព្រៃ

- រៀបសំរួលដោយ : សេង សុិន្តារ
- បោះផ្សាយដោយ : អង្គការ សុីប៉ា
- ជំនួយ

បណ្ណាល័យកុមារ : ខេត្តកំពង់ឆ្នាំង

៣០ / ០១ / ៩៤

គីម ជាក្មេងកំព្រា ដែល

ត្រូវបានលោកសង្ឃ រើសយក

មកចិញ្ចឹមបីបាច់រក្សា អោយ

រៀនសូត្រនៅក្នុងវត្ត ។ វាជា

ក្មេងឆ្លាតវៃ ហើយឧស្សាហ៍

ធ្វើការងារណាស់ ។



លុះមានអាយុ ១៣ឆ្នាំ
តឹម បានសុំការ អនុញ្ញាតពី
លោកគ្រូចៅអធិការវត្តទៅ
ប្រកបរបរ ចិញ្ចឹមជីវិតដោយ
ខ្លួនឯង ។



គឺមគ្មានស្រែ

ចំការទឹងគេទេ ។ វាបាន

ទៅសុំជួលដីអ្នកតាព្រៃ នៅ

ចុងភូមិដាំដំណាំ ។ អ្នកតាព្រៃ

នេះ មានដី១ហិចតា ដែលគ្មាន



ប្រជាជនណា ហ៊ានទៅជិតទេ

ព្រោះខ្លាចអ្នកតាព្រៃនេះកាច ។

តាយល់ព្រមដោយដាក់ល័ក្ខខ័ណ្ឌថា ÷

- ក្នុងឆ្នាំទី១នេះ គាត់យកផលណាដែល នៅលើដី ផលក្នុងដីអោយ តឹម ទាំងអស់ ។



គឺមបានកាប់គាស់ដីដោយគ្មានគិតពីការនឿយហត់ ។ បន្ទាប់មកវាបានទៅសុំខ្ចីប្រាក់លោកចៅអធិការវត្ត ដើម្បី ទិញ ដើមដំឡូងជ្វា និង ដំឡូងមីដាំ ។



លុះដល់ពេលដំឡូងអោយផល

គីម បាន ប្រាប់ អ្នកតា អោយ

ទៅប្រមូលស្លឹកដំឡូង ព្រោះខ្លួន

ដល់ពេល គាស់ដំឡូងហើយ ។



អ្នកតាខឹងណាស់ គាត់និយាយថាៈ

- នៅឆ្នាំទី២ គាត់យកផលនៅក្នុងដី

ទាំងអស់ ឯផលលើដី គាត់អោយ

ទៅគីម ។



ពេលភ្លៀងធ្លាក់ គឹមបាន

ភ្ជួររាស់ដី សាប ស្ទូងស្រូវ ដូច

កសិករនានា ។ ស្រូវរបស់គឹម





លូតលាស់ល្អណាស់ ។ លុះច្រូតកាត់

រួច គឹម បានទៅប្រាប់អ្នកតា អោយ

មកយកផល នៅក្នុងដី ដែលមានតែ

ឫស និង ជញ្ជ្រាំងស្រូវ ប៉ុណ្ណោះ ។



អ្នកតាខឹងខ្លាំងមែនទែន ព្រោះគាត់អត់បានផលអ្វីសោះពីរឆ្នាំមកហើយ ។ នៅឆ្នាំទី៣ គាត់ទាមទារយកផលនៅក្នុងដី និង ផលនៅ ខាងចុងដើម ហើយអោយ តឹម នូវផលដែល មានកណ្តាលដើម ។



នៅឆ្នាំទីពនេះ គឺមជ្រើសរើសយកដំណាំពោត និង អំពៅមកដាំ ។ ពោត និង អំពៅ ដុះលូតលាស់ល្អណាស់ ។



លុះពោត និង អំពៅ ហុចផលហើយ
តឹមបានទៅ អញ្ជើញលោកតា អោយមក
មើលខ្លួន ប្រមូលផលនៅ កណ្តាលដើម
គឺផ្លែពោត និង ដើមអំពៅ ចំណែកចុងពោត
ចុងអំពៅ ឫសពោត និង ឫសអំពៅ
តឹម ប្រគល់អោយ ទៅអ្នកតាព្រៃ
ទាំងអស់ ។

LIBRARY
BUDDHIST INSTITUTE



អ្នកតាព្រៃតូចចិត្ត នឹកខ្មាស

គេណាស់ ព្រោះគាត់ចាញ់ប្រាជ្ញាកុមារ តឹម

ក៏គេចខ្លួន បាត់ទៅ ។ ចាប់ពីពេលនោះមក

គេក៏ លែង ឃើញមានអ្នកតាព្រៃទៀត ។

បើឃើញ ក៏ឃើញតែរូបឈើ ឬ ថ្ម

ដែលគេលើក បន្ទុប ជាតំណាង តែ

ប៉ុណ្ណោះ ។



ក្រោយពីអ្នកតាព្រៃ
រត់ទៅបាត់ទៅ តឹមបានបន្តការ
បង្កបង្កើនផល លើដីនោះ
ហើយ សន្សំបានប្រាក់ សង់
ទីលំនៅរស់នៅយ៉ាងសុខសប្បាយ
តទៅ ។



បោះពុម្ពផ្សាយដោយ អង្គការ ស៊ីប៉ា SIPAR

រឿង

# តាហោរ និង តាចាស់ឆ្លូងចាស់

រៀបចំរូបដោយ : ទឿ យ៉ាត



SIPAR Prey Veng

តាមសៀវភៅប្រជុំរឿងព្រេងខ្មែរ
ដែលបោះពុម្ពផ្សាយដោយ ពុទ្ធសាសនបណ្ឌិត
គូរដោយ : ប៉ុល សារឿន


កាលពីព្រេងនាយ មាន
តាហោរម្នាក់ ចេះទស្សន៍ទាយ
ឆុតឆាប់ពូកែល្បីល្បាញ



ជារៀងរាល់ថ្ងៃ គេតែងតែឃើញអ្នក ភូមិផង របង ជាមួយ ព្រមទាំងអ្នកស្រុកជិត ឆ្ងាយចូលទៅពឹងពាក់ អាស្រ័យអោយគាត់ដោះស្រាយ បញ្ហាផ្សេងៗ គ្មានលោះថ្ងៃណា មួយឡើយ ។



មិនឆ្ងាយពីផ្ទះ តាហោរប៉ុន្មានមាន តា យាយ ប្ដី ប្រពន្ធ ពីរនាក់ រស់នៅលើដី ភូមិមួយ មានដំណាំ ដាំដុះគ្រប់មុខ សព្វសារពើ សំរាប់ជីវភាពប្រចាំថ្ងៃ ។





ថ្ងៃនេះតាំងពីព្រលឹម តាដាក់អង្រុត លើស្មា ។ តា យាយ ស្រុះស្រួលបបួលគ្នាទៅ នេសាទត្រី ក្នុងបឹង មួយតាមទំលាប់ ។



បឹងនេះជាបឹងសម្បូរត្រី ឋិតនៅក្នុងព្រៃ មិនឆ្ងាយពីភូមិ ដែលអ្នកស្រុក តែងតែទៅនេសាទ ពុំសូវលោះ ។





ជាភ័ព្វវាសនាល្អ ទៅដល់បឹងភ្នាម យាយ យើង ឃើញ ទន្សាយមួយ ដេកស្តូក សន្លប់ លើ ដីទួលមួយ ក្បែរមាត់បឹង។ យាយយើង ចាប់ចងទន្សាយ យក មក ដាក់ក្នុងល្អី ឥតស្តី មួយម៉ាត់ ។

និយាយពី តាយើងដែលនៅក្នុងបឹង គ្រាំចុះ គ្រាំឡើង រុតបានត្រីរស់មួយ ប៉ុនកំភួនដៃ ចាប់ចំ ស្រកី ដាក់ក្នុងទ្រុង រួចក៏ស្រែកហៅ យាយ អោយ មក សំរាក ។



តា យាយយើង បានមកអង្គុយសំរាក ក្រោមដើមឈើមួយ ។ យាយញញឹម និង អួតប្រាប់ តាពីការ រើសបានទន្សាយមួយ ធាត់ ទ្រលុក ។ ចំណែកតាយើងក៏មិនសុខចិត្ត ប្រឹងតបវិញយ៉ាងប្រញាប់ថាត្រីរ៉ស់ ក៏មិនស្គមល្មមឆ្ងាញ់ឥតចាញ់ទន្សាយយាយ ។

តា យាយសែនសប្បាយចិត្ត នឹកស្រមៃ ដល់ចំហាយក្លិនឆ្ងាញ់នៃម្ហូបសំលម្ជូរ ទន្សាយ និង ត្រីស្ងោរ ។



ពេលរសៀលទន់ទាប

ទើប តា យាយ យើង

ចៅរ៉ៅ វិលមកផ្ទះវិញ ។





តាយកអង្រុតទៅក្រុងទន្សាយ ។



ឯយាយយកទ្រុងត្រីរស់ ទៅប្រស់ទុក ក្នុងថ្លុក ជិតផ្ទះ ។



យប់នោះតា យាយពិគ្រោះគ្នាថា ÷

- យើងគិតសាកល្បងតាហោរ !. . .  តើគាត់ទាយត្រូវ រឺ មិនត្រូវ ? បើទាយត្រូវ យើងចាត់ទុកថាគាត់ពូកែ !...

លុះព្រឹកឡើង តា យាយ ក៏នាំគ្នាត្រសង ទៅកាន់ ផ្ទះតាហោរ

- នាងអើយ ! តាហោរនៅផ្ទះទេ ?

- ចាំស ! គាត់នៅទេ អញ្ជើញ តា យាយឡើងមក !



- តា យាយ មានការអ្វីទាំងព្រឹកដូចនេះ?

- បាទ ! យើងខ្ញុំសូមលោកតាជួយ គន់គូរ មើល តើខ្ញុំនៅតែគ្មានអ្វីហូបដូចនេះរឺ ? ជាពិសេសថ្ងៃនេះ ណាំលោកតា !..

តាហោរក៏ចាប់ដីស និងក្ដារឆ្នួនមកគូស ផ្ទួនៗ លេខអត្ថៈ រាប់ដៃ រាប់ជើង និង ធ្វើមាត់ ជីបអូចៗ ហើយក៏ដាក់ក្ដារចុះដូចភ្ញាក់ រួច សញ្ជឹងគិត ។



មួយស្របក់ក្រោយមក តាហោរ សើចញ្ញឹមៗ ហើយស្រដីថា÷

- អូហ៏ ! បើតាមជើងលេខ ជតាថ្ងៃនេះ យាយនិងតា នៅតែគ្មាន ម្ហូបអ្វីជាពិសេសសោះ ក្រៅពីប្រហុកខ្ទោះ ក្នុងពាងដែលមាន ស្រាប់នោះ ។

តា យាយហួសចិត្ត ហើយគិតថា ÷

"តាហោរនេះ គ្មានពូកែអ្វីទេ" តា យាយ ក៏លា លោកតាហោរ មកផ្ទះទាំងចិត្តចំអក ឡកឡឺយផង ។



មកដល់ផ្ទះ តាយើងរូតរះទៅមើលត្រី ។

ទៅដល់ចាប់ត្រីហើយដាក់លើដីរួច

ស្រែកហៅ យាយអោយយកកាំបិត ។

ត្រីលោតចូលថ្លុក តាស្ទុះទៅមុខតាម

ចាប់ ត្រីមុជចុះជ្រៅខាន

តាចាប់ តែតាប្រញាប់

រត់រកអង្រុត ។



តាឆក់បានអង្រុត ស្ទុះរត់វឹង ភ្លេចទន្សាយឈឹងដែលគាត់ក្រុង ។ ទន្សាយរួចខ្លួនបោលស្ទុះក្ដុងលឿនស្លុងចូលព្រៃចោល តា យាយ ។



តា យាយធ្វើមុខជូរហួញអស់សង្ឃឹម ក៏បបួលគ្នាទៅដាំបាយ ហើយចំហុយប្រហុក មួយចានធំ ។ ឆ្អិនហើយ តា យាយ អង្គុយ ទល់មុខគ្នា តាមើលមុខយាយទាំងហួសចិត្ត ថា៖

*"តាចោរ ពូកែមែន"*

*ត្រីរស់ក៏រួច ឆន្ទ្រាយក៏រួច ។*

**ចប់**







VENTE INTERDITE
Not for Sale
ហាមលក់

REPRODUCTION INTERDITE
No Copy Allowed
ហាមថតចម្លងបោះពុម្ព